ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តបាត់ដំបង
សំណុំរឿងរដ្ឋប្បវេណី
លេខ ៩១ អ ក ចុះថ្ងៃទី ២០
ខែ មីនា ឆ្នាំ ២០០៦

សាលក្រម
លេខ ៧៤ ក ចុះថ្ងៃទី ១៩
ខែ ឧសភា ឆ្នាំ ២០០៦

# តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅទាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក[redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក[redacted]ជាព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៩១ អ ក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ដែលមាន :

កម្មវត្ថុបណ្តឹង : **ប្តឹងទាមទារប្រាក់ចំនួន ១លានរៀល និង ការប្រាក់តាមច្បាប់កំណត់ ។ បណ្តឹងបន្ថែមទារជម្ងឺចិត្តចំនួន ៥០០.០០០៛០០ ។**

រវាងដើមចោទឈ្មោះ **ព ត** ភេទប្រុស អាយុ ៦៧ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីអាចារ្យ មានទីលំនៅសព្វថ្ងៃនៅភូមិចំការសំរោង ឃុំចំការសំរោង ស្រុកបាត់ដំបង ឪពុកឈ្មោះ **ព ឃ** (ស) ម្តាយឈ្មោះ **ស ស** (រ) មានប្រពន្ធឈ្មោះ **ម សទ** មានកូន ០៦នាក់ មានឈ្មោះ **ព សត** ជាតំណាង ។

និង ចុងចម្លើយឈ្មោះ **ព សម** ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីធ្វើស្រែ មានទីលំនៅសព្វថ្ងៃនៅភូមិចំការសំរោង ឃុំចំការសំរោង ស្រុកបាត់ដំបង ឪពុកឈ្មោះ **ឱ ព** (រ) ម្តាយឈ្មោះ **យ ត** (រ) មានប្រពន្ធឈ្មោះ **ម រ** មានកូន ០៨នាក់ ។

និង ចុងចម្លើយឈ្មោះ **ម រ** ភេទស្រី អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិចំការសំរោង ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ **ម** (ស) ម្តាយឈ្មោះ.....ប្តីឈ្មោះ **ព សជ** មានកូន ០៨នាក់ ។

បានឃើញរបាយការណ៍ជូនរឿងទៅជំនុំជំរះលេខ ៦៨១ ពសរតវ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦ របស់ចៅក្រមស៊ើបសួរតុលាការខេត្តបាត់ដំបង ។

**នាពេលសវនាការ**

-ឈ្មោះ **ព សត** ជាតំណាងផ្ទេរសិទ្ធិអោយដើមចោទឈ្មោះ **ព ត** បានឆ្លើយ

ថា ខ្លួនតំណាងអោយឪពុកខ្លួន ឈ្មោះ ពា ត ។ មកដល់ពេលនេះ ខ្លួនប្តឹងសុំទាមទារប្រាក់ពីឈ្មោះ ពា សខ និង ប្រពន្ធឈ្មោះ ម រ ដែលមានប្រាក់ដើមចំនួនមួយលានរៀល និង ការប្រាក់តាមច្បាប់កំណត់ ដោយគិតពីថ្ងៃអោយប្រាក់មកនៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ រហូតមកដល់ថ្ងៃកាត់ក្តីនេះ ។ ប្រាក់នេះជាប្រាក់ខ្ចីចងការបានធ្វើកិច្ចសន្យាត្រឹមត្រូវ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ ដោយកំណត់យកការប្រាក់ក្នុងមួយខែ ១៥ម៉ឺនរៀល និង បានកំណត់សងវិញក្នុងរយៈពេលតែ ០៣ខែទេ តែដល់ថ្ងៃកំណត់សងអ្នកទាំងពីរនៅតែមិនសងខ្លួនដដែល ។ ឪពុកខ្លួនបានទទួលការប្រាក់ចំនួន ០១ខែហើយ ។ ខ្លួនសុំទាមទារជម្ងឺចិត្តបន្ថែមទៀតចំនួន ៥០ម៉ឺនរៀល ព្រោះខ្លួនខាតបង់ពេលវេលាក្នុងការរកស៊ីរបស់ខ្លួន ។ ខ្លួនសំណូមពរសុំទាមទារប្រាក់ជំពាក់អោយបានគ្រប់ចំនួន បើចុងចម្លើយទាំងពីរនាក់គ្មានប្រាក់សងទេ សុំអោយតុលាការរឹបអូសទ្រព្យសម្បត្តិរបស់ចុងចម្លើយលក់ឡាយឡុងយកប្រាក់សងបំណុលអោយខ្លួន ក្នុងករណីដែលចុងចម្លើយរឹងរូសសុំអោយតុលាការដាក់គុកបង្ខំដល់រូបកាយចុងចម្លើយទាំងពីរនាក់ដើម្បីបង្ខំទារបំណុលអោយខ្លួនអោយបានគ្រប់ចំនួនដែលជំពាក់ ។

-ឈ្មោះ ពា សខ ជាចុងចម្លើយបានឆ្លើយថា ខ្លួន និង ប្រពន្ធខ្លួនពុំមានជាប់សាច់ឈាមអ្វីជាមួយម្ចាស់បំណុល ឈ្មោះ ពា ត នោះទេ គ្រាន់តែស្គាល់គ្នាប៉ុណ្ណោះ ។ ខ្លួនបានខ្ចីប្រាក់មែន គឺចំនួនប្រាក់ដើមមួយលានរៀល និង បានធ្វើកិច្ចសន្យាត្រឹមត្រូវដែរ ។ ខ្លួនបានឡើងការប្រាក់អោយបានចំនួនមួយខែហើយ គឺ ១៥ម៉ឺនរៀល ។ ឯប្រាក់ដើមនោះខ្លួនមិនបានសងទេ ។ មកដល់ពេលនេះខ្លួនសុខចិត្តអោយការប្រាក់តាមច្បាប់កំណត់ ឯជម្ងឺចិត្តមិនសុខចិត្តអោយទេ តែខ្លួនសុំអោយតុលាការសំរេចជម្ងឺចិត្តនេះតាមច្បាប់ចុះ ។ សព្វថ្ងៃនេះខ្លួនពុំមានប្រាក់សងទាំងដុំទេ ខ្លួនសុំសងប្រាក់នេះ ដោយសុំសងរំលោះទាំងដើមទាំងការក្នុងមួយខែចំនួន ៥០.០០០រៀលរហូតដល់សងអស់បំណុលនេះ ។

-ឈ្មោះ ម រ ជាចុងចម្លើយបានឆ្លើយថា ខ្លួនក៏ឯកភាពតាមចម្លើយរបស់ប្តីខ្លួនដូចការឆ្លើយនេះដែរ ។ ចំពោះសំណូមពររបស់ដើមចោទក្នុងបញ្ហារឹបអូសទ្រព្យសម្បត្តិរបស់ខ្លួនលក់ឡាយឡុង និង សុំដាក់គុកខ្លួននោះ ខ្លួនពុំមានអ្វីដោះស្រាយទេក្នុងរឿងនេះ ។

## តំណាងអយ្យការបានផ្តល់មតិសន្និដ្ឋានថា

-យល់ឃើញថា រឿងក្តីនេះជារឿងកិច្ចសន្យាខ្ចីប្រាក់ ជារឿងរដ្ឋប្បវេណីមិនប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈទេ សូមលោកចៅក្រមសំរេចតាមច្បាប់ ។

-បានឃើញសេចក្តីផ្សះផ្សា

-បានស្តាប់តំណាងដើមចោទប្តឹងសុំ ឆ្លើយអោយការ សំអាងហេតុ

-បានស្តាប់ចម្លើយដោះសាររបស់ចុងចម្លើយទាំងពីរនាក់

-បានស្តាប់ការសួរដេញដោលតទល់

-បានពិនិត្យកំណត់ហេតុ ឯកសារ ភស្តុតាងនានា

-បានស្តាប់យោបល់របស់តំណាងអយ្យការ

-បានពិចារណាត្រឹមត្រូវហើយ

## តុលាការខេត្តកណ្តាល

## យល់ឃើញថា

-បណ្តឹងចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦ របស់ឈ្មោះ ពា ត ប្តឹងទាមទារប្រាក់ដើមចំនួន ១.០០០.០០០រ៛០០

និង ប្រាក់ចុងការពីឈ្មោះ ៣ សម និង ឈ្មោះ ម រ ធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-លិខិតផ្ទេរសិទ្ធិដើរក្តី ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦ របស់ឈ្មោះ ៣ ត ផ្ទេរសិទ្ធិអោយឈ្មោះ ៣ សត ត្រូវជាកូនបង្កើតរបស់គាត់ដើរក្តីជំនួសធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ច្បាប់ ។

-ឈ្មោះ ៣ សម និង ឈ្មោះ ម រ ពិតជាជំពាក់ប្រាក់ដើមចោទពិតប្រាកដមែន ។ តែដោយចុងចម្លើយទាំងពីរនាក់ប្តីប្រពន្ធបានបង់ការប្រាក់បានចំនួន ១៥០.០០០រ០០រួចហើយ និង គិតការប្រាក់រយៈពេល ០១ឆ្នាំ ដើមចោទត្រូវទទួលបានតែ ៥០.០០០រ០០តែប៉ុណ្ណោះ ដូច្នេះការប្រាក់ដែលដើមចោទបានទទួលលើសកំណត់ច្បាប់ ត្រូវគិតជាប្រាក់ដើមចំនួនតែ ៩០០.០០០រ០០ទៀតតែប៉ុណ្ណោះ ។

-ការសំអាងហេតុរបស់តំណាងដើមចោទលើកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៦ ដែលចុងចម្លើយបានធ្វើជាមួយដើមចោទ ជាសំអាងហេតុមានភស្តុតាងបញ្ជាក់ច្បាស់លាស់អាចអោយតុលាការជឿបាន ។

-ទំនាក់ទំនងខ្ចីចងការប្រាក់ដើមចោទ និង តំណាងដើមចោទប្តឹងទារការប្រាក់ពីចុងចម្លើយជាការត្រូវច្បាប់នូវការទារការប្រាក់តាមកំណត់ច្បាប់ ៥ភាគរយក្នុងមួយឆ្នាំ គឺស្មើនឹង ៥០.០០០រ០០ ។ ការប្រាក់ចុងចម្លើយបានសងអោយដើមចោទរួចហើយ ។

-តំណាងដើមចោទបានប្តឹងបន្ថែមទារជម្ងឺចិត្តចំនួន ៥០០.០០០រ០០ពីចុងចម្លើយ ធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ហើយតែមានចំនួនច្រើនណាស់ ។

-ចម្លើយដោះសាររបស់ចុងចម្លើយ ០២នាក់ប្តីប្រពន្ធបានឆ្លើយទទួលស្គាល់ថា ខ្លួនពិតជាបានខ្ចីចងការប្រាក់ពីដើមចោទឈ្មោះ ៣ ត និង ឈ្មោះ ស ខណ នូវប្រាក់ដើមចំនួន ០១លានរៀល និង កំណត់ការប្រាក់ ១៥០.០០០រ០០ក្នុងមួយខែ ។ ដោយមិនទាមទារសងប្រាក់ដើមអោយដើមចោទទេ ទើបតែបានសងប្រាក់ចុងការមួយខែបានចំនួន ១៥ម៉ឺនរៀល ។ ជាចម្លើយដោះសារហុចប្រយោជន៍ទាំងស្រុងទៅខាងដើមចោទ ។

-ចុងចម្លើយសុំសងបំណុលអោយទៅដើមចោទសរុបនូវប្រាក់ដើម និង ការប្រាក់ដោយសុំសងរំលោះតាមខែក្នុង ០១ខែ១ចំនួន ៥០.០០០រ០០ រហូតដល់រួចបំណុលជាសំណូមពរធ្វើឡើងខុសនឹងគតិច្បាប់ ។

-កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ របស់គូភាគីធ្វើឡើងបានត្រឹមត្រូវតាមច្បាប់ ។

-សំណូមពររបស់តំណាងដើមចោទប្តឹងសុំអោយតុលាការ សំរេចរឹបអូសទ្រព្យសម្បត្តិរបស់ចុងចម្លើយលក់ឡាយឡុងយកប្រាក់សងបំណុលអោយខ្លួនក្នុងករណីចុងចម្លើយគ្មានប្រាក់សង និង ក្នុងករណីចុងចម្លើយរឹងរូសសុំឱ្យតុលាការសំរេចដាក់គុកបង្ខំដល់រូបកាយចុងចម្លើយទាំងពីរនាក់ ដើម្បីបង្ខំទារបំណុលអោយខ្លួនធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-ចុងចម្លើយជាភាគីមានកំហុស ដូច្នេះគាត់ត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១-ក-ទទួលបណ្តឹងចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៥ របស់ឈ្មោះ ៣ ត ប្តឹងទារប្រាក់ដើម និង ប្រាក់ចុងការ តាមកំណត់ច្បាប់ពីឈ្មោះ ៣ សម និង ឈ្មោះ ម រ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

ខ- ទទួលលិខិតផ្ទេរសិទ្ធិដើរក្តី ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦ របស់ឈ្មោះ ៣ ត ផ្ទេរសិទ្ធិអោយឈ្មោះ ៣ សត ត្រូវជាកូនបង្កើតរបស់គាត់ដើរក្តីជំនួស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

គ-ទទួលបណ្តឹងបន្ថែមរបស់តំណាងដើមចោទ ប្តឹងទារជម្ងឺចិត្តពីចុងចម្លើយទាំងពីរនាក់ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

ឃ-ទទួលសំណូមពររបស់តំណាងដើមចោទ ប្តឹងសុំអោយតុលាការសំរេចរឹបអូសទ្រព្យសម្បត្តិរបស់ចុងចម្លើយលក់ឡាយឡុងយកប្រាក់សងបំណុលអោយខ្លួន ក្នុងករណីចុងចម្លើយគ្មានប្រាក់សង និង ក្នុងករណីចុងចម្លើយរឹងរូសសុំអោយតុលាការសំរេចដាក់គុកបង្ខំដល់រូបរាងកាយ ដើម្បីបង្ខំទារបំណុលឱ្យខ្លួនទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

ង-បដិសេធចោលទាំងស្រុងនូវសំណូមពររបស់ចុងចម្លើយ ដែលបានប្តឹងសុំសងបំណុលអោយទៅដើមចោទ ដោយសងរំលោះតាមខែក្នុងមួយខែៗចំនួន ៥០.០០០រ;០០ រហូតដល់រួចបំណុល ដោយខុស និង គតិច្បាប់ ។

២-អោយឈ្មោះ ៣ សម និង ឈ្មោះ ម រ សងបំណុលអោយទៅឈ្មោះ ៣ ត នូវ :

-ប្រាក់ដើមចំនួន ៩០០.០០០រ;០០ ( ប្រាំបួនរយពាន់) រៀលគត់ ។

-ជម្ងឺចិត្តចំនួន ១០០.០០០រ;០០ ( មួយរយពាន់) រៀលគត់ ។

-ដើមចោទ និង តំណាងដើមចោទទារលើសពីនេះបដិសេធចោល ។

-ក្នុងករណីឈ្មោះ ៣ សម និង ឈ្មោះ ម រ គ្មានប្រាក់សងបំណុលអោយទៅដើមចោទត្រូវរឹបអូសទ្រព្យសម្បត្តិសាមីចុងចម្លើយទាំងពីរនាក់ លក់ឡាយឡុងយកប្រាក់សងអោយទៅឈ្មោះ ៣ ត ជាដើមបំណុល ។

-ក្នុងករណីចុងចម្លើយឈ្មោះ ៣ សម និង ឈ្មោះ ម រ រឹងរូសមិនព្រមសងបំណុលអោយទៅដើមចោទត្រូវដាក់គុកបង្ខំដល់រូបកាយដើម្បីបង្ខំទារបំណុលឱ្យទៅដើមបំណុលឈ្មោះ ៣ ត ។

-តាមបទបញ្ញត្តិមាត្រា៤.២២.៥៦.៥៧.៦០ នៃក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

-តាមបញ្ញត្តិមាត្រា ១. ១២៥. ១២៦. ១២៧. ១២៨ និង ១៣៣ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៥១ក្រ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩២ ។

៣-អោយឈ្មោះ ៣ សម និង ឈ្មោះ ម រ បង់ប្រដាប់ក្តីចំនួន ៧.០០០រ;០០ ប្រាក់នេះចំណាយបង់ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន ១.៨០០រ;០០ ចំណាយរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០រ;០០ ចំណាយក្នុងកិច្ចស៊ើបសួរចំនួន ៥.០០០រ;០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ៧.០០០រ;០០ ដែលដើមចោទបានបង់ទុកមុនរួច ហើយកាលបើសាលក្រមនេះចូលជាស្ថាពរអោយឈ្មោះ ៣ សម និង ឈ្មោះ ម រ សងប្រាក់ ៧.០០០រ;០០ អោយទៅដើមចោទវិញ ។

-និងអោយឈ្មោះ ៣ សម និង ឈ្មោះ ម រ បង់ពន្ធសមាមាត្រចំនួន ១០.០០០រ;០០ ។

-តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខតំណាងដើមចោទ និង ចុងចម្លើយទាំងពីរនាក់ ។

បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែគិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជំរះ**

[redacted] [redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បង្គាប់មកអ្នកអនុវត្តសាលក្រមអោយបានសំរេចតាមសាលក្រមនេះ និង អោយអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ជួយអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៦*

**ជ.ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

*បាត់ដំបង, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៦*

**ប្រធានតុលាការខេត្ត**

[redacted]